ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 7

# របាយការណ៍លំហូរសាច់ប្រាក់

## Statements of Cash Flows

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# អារម្ភកថា

ដោយសារនយោបាយ “**ឈ្នះ-ឈ្នះ**” របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា **“យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣”, “ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨”, “យុទ្ធសាស្ត្រត្រីកោណ”, “យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០”** និង **“យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨”** ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និង ក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី **“ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ”** ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# **អារម្ភកថា**

៚៙៚

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន“ *ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង “*ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម*” ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ងី តាយី**

**គោលបំណង**

ព័ត៌មានស្តីពី លំហូរសាច់ប្រាក់របស់អង្គភាពមួយ ផ្តល់ប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនូវមូលដ្ឋាន ដើម្បីវាយតម្លៃលទ្ធភាពរបស់អង្គភាពក្នុងការបង្កើតសាច់ប្រាក់និងសាច់ប្រាក់ប្រហាក់ប្រហែល និងតម្រូវការរបស់អង្គភាពក្នុងការប្រើប្រាស់លំហូរសាច់ប្រាក់ទាំងនោះ។ ការសម្រេចចិត្តតាមបែបសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ទាំងឡាយទាមទារឱ្យមានការវាយតម្លៃលទ្ធភាពរបស់អង្គភាពមួយក្នុងការបង្កើតសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល ហើយនិងការកំណត់ពេលវេលា និងភាពប្រាកដប្រជានៃការបង្កើតសាច់ប្រាក់របស់អង្គភាពនានា ។

គោលបំណងរបស់ស្តង់ដានេះ គឺដើម្បីទាមទារការផ្តល់ព័ត៌មានស្តីពី បម្រែបម្រួលសាច់ប្រាក់ដើម និងសាច់ប្រាក់ប្រហាក់ប្រហែលរបស់អង្គភាពមួយទៅតាមរយៈរបាយការណ៍លំហូរសាច់ប្រាក់ ដោយធ្វើចំណាត់ថ្នាក់លំហូរសាច់ប្រាក់ក្នុងការិយបរិច្ឆេទ ទៅតាមសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគ និងសកម្មភាពហិរញ្ញប្បទាន។

**វិសាលភាព**

**១ អង្គភាពមួយត្រូវរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ ដោយអនុលោមទៅតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារនេះនិងត្រូវបង្ហាញរបាយការណ៍ នេះជាផ្នែកមួយ យ៉ាងសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយ-បរិច្ឆេទនៃរបាយការណ៍ ហិរញ្ញវត្ថុដែលបានបង្ហាញ។**

២ ស្តង់ដានេះបានជំនួស ស.គ.អ ៧ *របាយការណ៍បម្រែបម្រួលស្ថានភាពហិរញ្ញវត្ថុ* ដែលត្រូវបានអនុម័តក្នុងខែកក្កដា ឆ្នាំ១៩៧៧។

៣ អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ របស់អង្គភាពមួយមានចំណាប់អារម្មណ៍ពី វិធីដែលអង្គភាពនោះ ធ្វើការបង្កើត និងប្រើប្រាស់សាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល។ នេះជាករណីមួយដោយ មិនគិតពីលក្ខណៈនៃសកម្មភាពរបស់អង្គភាព និងមិនគិតថាតើ សាច់ប្រាក់អាចចាត់ទុកជាលទ្ធផលរបស់អង្គភាព ដូចជាករណីរបស់ស្ថាប័នហិរញ្ញវត្ថុ។ អង្គភាពត្រូវការសាច់ប្រាក់ក្នុងហេតុផលចាំបាច់ដូចៗគ្នា ទោះបីជាសកម្មភាពជាមូលដ្ឋានក្នុងការរកប្រាក់ចំណូលរបស់គេអាចខុសគ្នាក៏ដោយ។ អង្គភាពត្រូវការសាច់ប្រាក់សម្រាប់ប្រតិបត្តិការសម្រាប់សងបំណុលនិងដើម្បីផ្តល់ប្រាក់ចំណេញទៅឱ្យ វិនិយោគិនរបស់ពួកគេ។ អាស្រ័យហេតុនេះហើយទើបស្តង់ដានេះតម្រូវឱ្យរាល់អង្គភាពទាំងអស់ ដាក់បង្ហាញរបាយការណ៍លំហូរសាច់ប្រាក់ ។

## អត្ថប្រយោជន៍នៃព័ត៌មានលំហូរសាចប្រាក់

៤ នៅពេលដែលរបាយការណ៍លំហូរសាច់ប្រាក់ ត្រូវបានប្រើរួមជាមួយរបាយការណ៍ផ្សេងៗទៀត នៃរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍លំហូរសាច់ប្រាក់មួយ ផ្តល់នូវព័ត៌មានដែលអាចផ្តល់លទ្ធភាពដល់អ្នកប្រើប្រាស់ទាំងឡាយ វាយតម្លៃលើបម្រែបម្រួលនៃ ទ្រព្យសកម្មសុទ្ធរបស់អង្គភាព រចនាសម្ព័ន្ធហិរញ្ញវត្ថុ (ដែលរួមមាន សន្ទនីយភាព និងសោធនភាព) និងលទ្ធភាពរបស់អង្គភាព ក្នុងការជះឥទ្ធិពលលើចំនួន និងការកំណត់ពេលវេលានៃលំហូរសាច់ប្រាក់ ដើម្បីធ្វើឱ្យស្របទៅតាមបម្រែបម្រួលកាលៈទេសៈ

និងឱកាស ។ ព័ត៌មានលំហូរសាច់ប្រាក់នេះ មានសារៈប្រយោជន៍ក្នុងការវាយតម្លៃលទ្ធភាពរបស់អង្គភាព ក្នុងការបង្កើតសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល ហើយវាក៏ជួយដល់អ្នកប្រើប្រាស់ ក្នុងការបង្កើតគំរូ ដើម្បីវាយតម្លៃ និងប្រៀបធៀបតម្លៃបច្ចុប្បន្ន នៃលំហូរសាច់ប្រាក់នាពេលអនាគតរបស់អង្គភាពផ្សេងៗគ្នា។ ព័ត៌មានលំហូរសាច់ប្រាក់នេះក៏ជួយធ្វើឱ្យការប្រៀបធៀប អំពីការរាយការណ៍លទ្ធផលប្រតិបត្តិការ របស់អង្គភាពផ្សេងគ្នាមានភាពកាន់តែប្រសើរឡើង ពីព្រោះវាបានលុបបំបាត់នូវ ការជះឥទ្ធិពល ដោយសារការប្រើប្រាស់ការធ្វើគណនេយ្យកម្មខុសៗគ្នា ចំពោះប្រតិបត្តិការ និងព្រឹត្តការណ៍មួយចំនួន ដែលមានលក្ខណៈដូចគ្នា ។

៥ ព័ត៌មានស្តីពីលំហូរសាច់ប្រាក់ប្រវត្តិសាស្ត្រ ជាញឹកញាប់ត្រូវបានប្រើប្រាស់ជាសូចនាករចង្អុលបង្ហាញពីចំនួនទឹកប្រាក់ ពេលវេលា និងភាពប្រាកដប្រជានៃលំហូរសាច់ប្រាក់នាពេលអនាគត។ ព័ត៌មាននេះក៏មានសារៈប្រយោជន៍ក្នុងការពិនិត្យពីភាពត្រឹមត្រូវអំពី ការវាយតម្លៃអតីតកាល ទៅលើលំហូរសាច់ប្រាក់ពេលអនាគត ហើយវាមានផលប្រយោជន៍ក្នុងការត្រួតពិនិត្យអំពី ទំនាក់ទំនងរវាង ភាពដែលអាចរកប្រាក់ចំណេញបាន និងលំហូសាច់ប្រាក់សរុប ព្រមទាំងឥទ្ធិពលនៃបម្រែបម្រួលថ្លៃ ។

## និយមន័យ

**៦ វាក្យស័ព្ទខាងក្រោម ដែលបានប្រើប្រាស់ក្នុងស្តង់ដានេះ មានអត្ថន័យ ជាក់លាក់ដូចតទៅ ÷**

*សាច់ប្រាក់* **រួមមានសាច់ប្រាក់ក្នុងដៃ និងបញ្ញើចរន្ត ។**

| | |
|---|---|
| *សាច់ប្រាក់ប្រហាក់ប្រហែល* | **ជាការវិនិយោគ ដែលមានរយៈពលខ្លី និងដែលអាចប្តូរជាសាច់ប្រាក់មកប្រើបានឆាប់រហ័ស ដោយអាចដឹងតម្លៃបាន និងមានហានិភ័យតូចតាចចំពោះបម្រែបម្រួលតម្លៃ ។** |
| *លំហូរសាច់ប្រាក់* | **ជាលំហូរចេញ និងលំហូរចូលនៃសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល ។** |
| *សកម្មភាពប្រតិបត្តិការ* | **គឺជាសកម្មភាព ជាចម្បងក្នុងការ បង្កើតចំណូលរបស់អង្គភាព និងសកម្មភាពផ្សេងៗ ទៀតដែលមិនមែនជាសកម្មភាពវិនិយោគ និងហិរញ្ញប្បទាន ។** |
| *សកម្មភាពវិនិយោគ* | **គឺជាការទិញ និងការលក់ទ្រព្យសកម្ម រយៈពេលវែង និងការវិនិយោគ ដទៃទៀតដែលមិនរាប់បញ្ចូលក្នុង សាច់ប្រាក់ប្រហាក់ប្រហែល ។** |
| *សកម្មភាពហិរញ្ញប្បទាន* | **ជាសកម្មភាពទាំងឡាយ ដែលធ្វើឱ្យមានការប្រែប្រួលដល់ទំហំ និងសមាសភាពនៃទ្រព្យម្ចាស់ភាគហ៊ុន និងកម្ចីរបស់អង្គភាព ។** |

## សាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល

៧ សាច់ប្រាក់ប្រហាក់ប្រហែល ត្រូវបានរក្សាទុក ដើម្បីប្រើប្រាស់ក្នុងគោលបំណងបំពេញបាននូវកាតព្វកិច្ចជាសាច់ប្រាក់រយៈពេលខ្លី ជាជាងសម្រាប់ការវិនិយោគ ឬបំណងផ្សេងទៀត។ ដើម្បីឱ្យការវិនិយោគមួយមានលក្ខណៈសម្បត្តិជាសាច់ប្រាក់ប្រហាក់ប្រហែល នោះវាត្រូវតែមានលទ្ធភាពជាស្រេច

ក្នុងការដែលអាចប្តូរជា តម្លៃជាសាច់ប្រាក់មួយ ដែលអាចដឹងជាមុន និងមានហានិភ័យបម្រែបម្រួលថ្លៃតូចតាច។ ដូច្នេះហើយ ជាធម្មតាការវិនិយោគមួយអាចត្រូវបានចាត់ទុកជាសាច់ប្រាក់ប្រហាក់ប្រហែលនៅពេលណាដែលវាមានកាលកំណត់សងរយៈពេលខ្លី ដែលអាចនិយាយថា រយៈពេល ៣ខែ ឬក៏មានរយៈពេលតិចជាងនេះ គិតចាប់ពីកាលបរិច្ឆេទនៃ ការវិនិយោគនោះ។ ការវិនិយោគលើមូលនិធិផ្ទាល់ត្រូវបានដកចេញពីសាច់ប្រាក់ប្រហាក់ប្រហែល លើកលែងតែខ្លឹមសារនៃ ការវិនិយោគនោះ គឺជាសាច់ប្រាក់ប្រហាក់ប្រហែល ឧទាហរណ៍ ក្នុងករណីភាគហ៊ុនបរិមាត្រូវបានទិញក្នុងរយៈពេលខ្លីនៃកាលកំណត់សង ព្រមទាំងមានកាលបរិច្ឆេទនៃការរំលោះសងជាក់លាក់ ។

៨ ការខ្ចីប្រាក់ពីធនាគារ ជាទូទៅត្រូវបានគេចាត់ទុកថាជា សកម្មភាពហិរញ្ញប្បទាន។ ក៏ប៉ុន្តែ នៅក្នុងប្រទេសខ្លះឥណទានវិបារូប៍ដែលត្រូវត្រលប់ទៅវិញទៅធនាគារវិញតាមតម្រូវការ គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការគ្រប់គ្រងសាច់ប្រាក់របស់អង្គភាព។ ក្នុងករណីបែបនេះ ឥណទានវិបារូប៍ត្រូវបានគេរួមបញ្ចូលជាសមាសភាគមួយនៃសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល។ លក្ខណៈនៃការរៀបចំរបស់ធនាគារ បែបនេះគឺថា សមតុល្យធនាគារតែងតែផ្លាស់ប្តូរពី សមតុល្យវិជ្ជមានទៅជាអវិជ្ជមាន ។

៩ លំហូរសាច់ប្រាក់ ដោយមិនរាប់បញ្ចូលចលនារវាងធាតុ ដែលបង្កើតជាសាច់ប្រាក់ ឬក៏សាច់ប្រាក់ប្រហាក់ប្រហែល ពីព្រោះសមាសភាគទាំងនេះគឺជាផ្នែកនៃការគ្រប់គ្រងសាច់ប្រាក់របស់ អង្គភាពមួយ ជាជាងផ្នែកនៃសកម្មភាព ប្រតិបត្តិការសកម្មភាពវិនិយោគ និងសកម្មភាពហិរញ្ញប្បទាន។

ការគ្រប់គ្រងសាច់ប្រាក់រួមមាន ការវិនិយោគសាច់ប្រាក់លើសក្នុងសាច់ប្រាក់ប្រហាក់ប្រហែល ។

## ការបង្ហាញរបាយការណ៍លំហូរសាច់ប្រាក់

**១០ របាយការណ៍លំហូរសាច់ប្រាក់ត្រូវតែរាយការណ៍ពីលំហូរសាច់ប្រាក់ក្នុងអំឡុងពេលនៃការិយបរិច្ឆេទ ដោយមានការចាត់ថ្នាក់តាមសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគ និងសកម្មភាពហិរញ្ញប្បទាន។**

១១ អង្គភាពមួយបង្ហាញពី លំហូរសាច់ប្រាក់ ដែលបានមកពីសកម្មភាពប្រតិ-បត្តិការ សកម្មភាពវិនិយោគ និងសកម្មភាពហិរញ្ញប្បទានក្នុងលក្ខណៈមួយដែលសមស្របបំផុតសម្រាប់អាជីវកម្មរបស់គេ ។ ការចាត់ថ្នាក់តាមសកម្មភាព ផ្តល់នូវព័ត៌មានដែលអាចឱ្យអ្នកប្រើប្រាស់វាយតម្លៃពីឥទ្ធិពលនៃសកម្មភាព ទាំងនេះមកលើស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព និងទៅលើសាច់ប្រាក់ និង សាច់ប្រាក់ប្រហាក់ប្រហែលរបស់វាបាន ។ ព័ត៌មាននេះក៏អាចត្រូវបានប្រើប្រាស់ ដើម្បីវាយតម្លៃទំនាក់ទំនងរវាងសកម្មភាពទាំងនោះផងដែរ ។

១២ ប្រតិបត្តិការតែមួយ អាចរួមបញ្ចូលនូវលំហូរសាច់ប្រាក់ ដែលត្រូវបានគេចាត់ថ្នាក់តាមសកម្មភាពដោយឡែកពីគ្នា។ ឧទាហរណ៍ នៅពេលដែលមានការសងបំណុលជាសាច់ប្រាក់ ដែលមានទាំងការប្រាក់ និងប្រាក់ដើម នោះការប្រាក់អាចត្រូវបានគេចាត់ថ្នាក់ជាសកម្មភាពប្រតិបត្តិការ ហើយប្រាក់ដើមត្រូវចាត់ថ្នាក់ជាសកម្មភាពហិរញ្ញប្បទាន។

## សកម្មភាពប្រតិបត្តិការ

១៣ ទឹកប្រាក់នៃលំហូរសាច់ប្រាក់ ដែលកើតមកពីសកម្មភាពប្រតិបត្តិការ គឺជាការចង្អុលបង្ហាញដ៏សំខាន់ អំពីវិសាលភាពប្រតិបត្តិការរបស់អង្គភាព ដែលបានបង្កើតលំហូរសាច់ប្រាក់គ្រប់គ្រាន់ សម្រាប់ទូទាត់សងបំណុល សម្រាប់រក្សាលទ្ធភាពប្រតិបត្តិការរបស់អង្គភាពសម្រាប់ទូទាត់ភាគលាភនិងសម្រាប់ការវិនិយោគទុនថ្មី ដោយពុំចាំបាច់ពឹងផ្អែកលើហិរញ្ញប្បទានពីប្រភពខាងក្រៅ ។ ព័ត៌មានស្តីពីសមាសភាគ ជាក់លាក់នៃប្រវត្តិ លំហូរសាច់ប្រាក់ប្រតិបត្តិការ រួមជាមួយនឹងព័ត៌មានដទៃទៀត មានសារៈប្រយោជន៍ក្នុងការព្យាករណ៍លំហូរសាច់ប្រាក់ពីប្រតិបត្តិការនាពេលអនាគត ។

១៤ លំហូរសាច់ប្រាក់របស់ សកម្មភាពប្រតិបត្តិការ គឺសំខាន់បំផុតបានមកពីសកម្មភាពបង្កើតចំណូលចំបង របស់អង្គភាព ។ ដូច្នេះហើយលំហូរសាច់ប្រាក់ទាំងនោះជាទូទៅគឺជាលទ្ធផលពីប្រតិបត្តិការ និងព្រឹត្តិការណ៍ដែលបានកត់ត្រាដើម្បីកំណត់ប្រាក់ចំណេញ ឬខាត ។ ខាងក្រោមនេះជាឧទាហរណ៍នៃលំហូរសាច់ប្រាក់ ដែលបានមកពីសកម្មភាពប្រតិបត្តិការ÷

(ក) សាច់ប្រាក់ដែលទទួលបានពីការលក់ទំនិញនិងការផ្តល់សេវាកម្ម។

(ខ) សាច់ប្រាក់ដែលទទួលបានពីសួយសារ ថ្លៃឈ្នួល កម្រៃជើងសារ និងចំណូលផ្សេងៗ ។

(គ) សាច់ប្រាក់ចំណាយ ឱ្យអ្នកផ្គត់ផ្គង់ និងសេវាកម្ម ។

(ឃ) សាច់ប្រាក់ចំណាយឱ្យនិយោជិក និងប្រាក់ចំណាយជំនួសនិយោជិក ។

(ង) សាច់ប្រាក់ចំណូល និងសាច់ប្រាក់ចំណាយរបស់ អង្គភាពធានារ៉ាប់រ៉ង ចំពោះបុព្វលាភ និងការទាមទារ ធនលាភ និងផលប្រយោជន៍គោលនយោបាយផ្សេងៗទៀត។

(ច) សាច់ប្រាក់ចំណាយ និងសាច់ប្រាក់បង្វិលសងត្រឡប់មកវិញនៃពន្ធលើប្រាក់ចំណេញ លុះត្រាតែសាច់ប្រាក់នោះ មិនអាចកំណត់បានច្បាស់លាស់ថាជា សកម្មភាពហិរញ្ញប្បទាន និងសកម្មភាពវិនិយោគ។

(ឆ) សាច់ប្រាក់ទទួលបាន និងសាច់ប្រាក់ចំណាយពីកិច្ចសន្យា ដែលទុកសម្រាប់គោលបំណងដោះដូរ ឬពាណិជ្ជកម្ម។

ប្រតិបត្តិការខ្លះដូចជាការលក់ធាតុមួយនៃរោងចក្រអាចនាំឱ្យមានការចំណេញ ឬខាតដែលត្រូវបានដាក់បញ្ចូលទៅក្នុងប្រាក់ចំណេញ ឬខាតដែលបានទទួលស្គាល់ ។ លំហូរសាច់ប្រាក់ទាក់ទងនឹងប្រតិបត្តិការនេះ គឺជាលំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពវិនិយោគ ។ ទោះជាយ៉ាងណាក៏ដោយ ប្រាក់ចំណាយដើម្បីផលិត ឬទិញទ្រព្យសកម្មដើម្បីទុកជួលឱ្យអ្នកដទៃ និងបន្តមកទៀតរក្សាទុកសម្រាប់លក់ ដូចដែលបានពណ៌នានៅក្នុង កថាខណ្ឌ ៦៨ក នៃ ស.គ.អ ១៦ *ទ្រព្យសម្បត្តិ រោងចក្រ និងឧបករណ៍* គឺជាលំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពប្រតិបត្តិការ ។ សាច់ប្រាក់ទទួលបានដែលបានមកពីការការជួលនិងការលក់នៃទ្រព្យសម្បត្តិទាំងនោះនាពេលបន្ទាប់ គឺជាលំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពប្រតិបត្តិការ ។

១៥ អង្គភាពមួយអាចរក្សាទុកមូលប័ត្រ និងកម្ចីដើម្បីធ្វើការដោះដូរ ឬការធ្វើពាណិជ្ជកម្ម ដែលក្នុងករណីនេះ វាមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅ

នឹងសន្និធិដែលត្រូវបានទិញជាពិសេសដើម្បីលក់បន្ត។ អាស្រ័យហេតុនេះ លំហូរសាច់ប្រាក់ពីការទិញ និងការលក់មូលប័ត្រសម្រាប់ជួញដូរ ត្រូវចាត់ថ្នាក់ជាសកម្មភាពប្រតិបត្តិការ។ ស្រដៀងគ្នានេះដែរ សាច់ប្រាក់បុរេប្រទាន និងកម្ចីដែលផ្តល់ដោយស្ថាប័នហិរញ្ញវត្ថុ ជាធម្មតាត្រូវបានគេចាត់ថ្នាក់ជាសកម្មភាពប្រតិបត្តិការ នៅពេលដែលសាច់ប្រាក់ទាំងនោះ ទាក់ទងនឹងសកម្មភាពបង្កើតចំណូលសំខាន់របស់អង្គភាពនោះ។

## សកម្មភាពវិនិយោគ

១៦ ការលាតត្រដាងដាច់ដោយឡែកពីគ្នានៃលំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពវិនិយោគមានសារៈសំខាន់ ពីព្រោះលំហូរសាច់ប្រាក់តំណាង ឱ្យវិសាលភាពនៃខ្ទង់ចំណាយណាមួយ ដែលត្រូវធ្វើឡើងសម្រាប់ជាធនធានដើម្បីបង្កើតចំណូល និងលំហូរសាច់ប្រាក់នាពេលអនាគត។ មានតែការចំណាយ ដែលនាំឱ្យទ្រព្យសកម្ម ត្រូវបានគេទទួលស្គាល់ក្នុងរបាយការណ៍ស្ថានការណ៍ហិរញ្ញវត្ថុទេទើបសមស្របសម្រាប់ការចាត់ថ្នាក់ជាសកម្មភាពវិនិយោគ។ ខាងក្រោមនេះជា ឧទាហរណ៍នៃលំហូរសាច់ប្រាក់បានមកពីសកម្មភាពវិនិយោគ÷

(ក) សាច់ប្រាក់ចំណាយសម្រាប់ទិញទ្រព្យ រោងចក្រ និងឧបករណ៍ ទ្រព្យសកម្មអរូបីនិងទ្រព្យសកម្មរយៈពេលវែងផ្សេងៗទៀត។ ការចំណាយទាំងនេះរួមមានការចំណាយដែលទាក់ទងនឹងថ្លៃដើមការអភិវឌ្ឍន៍ ដែលបានធ្វើមូលធនកម្ម និងទ្រព្យរោងចក្រ និងឧបករណ៍ ដែលត្រូវបានសាងសង់ដោយអង្គភាពខ្លួនឯង។

(ខ) សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ រោងចក្រ និងឧបករណ៍ ទ្រព្យសកម្មអរូបី និងទ្រព្យសកម្មរយៈពេលវែងផ្សេងៗទៀត។

(គ) ការចំណាយសាច់ប្រាក់ ដើម្បីទិញឧបករណ៍បំណុល ឬមូលធនផ្ទាល់ នៃអង្គភាពផ្សេងទៀត និងភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន (ក្រៅពីការចំណាយសម្រាប់ឧបករណ៍ទាំងឡាយ ដែលចាត់ទុកជាសាច់ប្រាក់ប្រហាក់ប្រហែលឬដែលរក្សាទុកសម្រាប់គោលបំណងជួញដូរ)។

(ឃ) សាច់ប្រាក់ទទួលបានពី ការលក់ឧបករណ៍បំណុល ឬមូលធននៃអង្គភាពផ្សេងទៀត និងអត្ថ ប្រយោជន៍នៅ ក្នុងអង្គភាពដាក់ហ៊ុនរួមគ្នា (ក្រៅពីការចំណាយសម្រាប់ឧបករណ៍ទាំងឡាយ ដែលចាត់ទុកជា សមមូលសាច់ប្រាក់ ឬ ដែលកាន់ទុកសម្រាប់គោលបំណងជួញដូរ) ។

(ង) សាច់ប្រាក់បុរេប្រទាន និងកម្ចីឱ្យទៅភាគីដទៃ (ក្រៅពីបុរេប្រទាន និងកម្ចីដែលត្រូវបាន ធ្វើឡើងដោយស្ថាប័នហិរញ្ញវត្ថុមួយ)។

(ច) សាច់ប្រាក់ទទួលបានពីការទូទាត់បុរេប្រទាន និងកម្ចីឱ្យទៅភាគីដទៃ (ក្រៅពីបុរេប្រទាន និងកម្ចី ដែលត្រូវបានធ្វើឡើងដោយស្ថាប័នហិរញ្ញវត្ថុមួយ) ។

(ឆ) សាច់ប្រាក់ចំណាយសម្រាប់កិច្ចសន្យានាពេលអនាគត កិច្ចសន្យានាពេលខាងមុខ កិច្ចសន្យាជម្រើស កិច្ចសន្យាប្តូរ លើកលែងតែនៅពេលដែលកិច្ចសន្យា ត្រូវបានរក្សាសម្រាប់ជួញដូរ ឬ ពាណិជ្ជកម្ម ឬការបង់ប្រាក់ទាំងឡាយណាដែលត្រូវបានគេចាត់ថ្នាក់ថាជាសកម្មភាពហិរញ្ញប្បទាន។ និង

(ឈ) សាច់ប្រាក់ចំណូល សម្រាប់កិច្ចសន្យានាពេលខាងមុខ កិច្ចសន្យាជម្រើសកិច្ចសន្យាប្តូរ លើកលែងនៅពេលដែលកិច្ចសន្យា ត្រូវបានរក្សាទុកសម្រាប់ជួញដូរ ឬ ពាណិជ្ជកម្ម ឬការទទួលប្រាក់ទាំងឡាយណាដែលត្រូវបានគេចាត់ថ្នាក់ ជាសកម្មភាពហិរញ្ញប្បទាន ។

នៅពេលដែលកិច្ចសន្យាត្រូវបានកត់ត្រាថាជា ការទប់ ស្កាត់ហានិភ័យនៃស្ថានភាពមួយដែលបានកំណត់ នោះលំហូរ សាច់ប្រាក់នៃ កិច្ចសន្យាត្រូវបានចាត់ថ្នាក់នៅក្នុងលក្ខណៈ ដូចគ្នាទៅនឹងលំហូរសាច់ប្រាក់នៃស្ថានភាពមួយដែលកំពុងត្រូវ បានទប់ស្កាត់ហានិភ័យ ។

## សកម្មភាពហិរញ្ញប្បទាន

១៧ ការលាតត្រដាងដាច់ដោយឡែកនៃ លំហូរសាច់ប្រាក់ ដែលបានមកពីសកម្មភាពហិរញ្ញប្បទានមានសារៈសំខាន់ណាស់ ពីព្រោះវាមានប្រយោជន៍សម្រាប់អ្នកផ្តល់មូលធនដល់អង្គភាព ក្នុងការព្យាករណ៍ លើការទាមទារដែលត្រូវទទួលបានពីលំហូរសាច់ប្រាក់នាពេលអនាគត។ ខាងក្រោមនេះជាឧទាហរណ៍ លំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពហិរញ្ញប្បទាន÷

(ក) សាច់ប្រាក់បានមកពីការបោះលក់ភាគហ៊ុន ឬ ឧបករណ៍មូលធនផ្សេងៗទៀត

(ខ) សាច់ប្រាក់ចំណាយឱ្យម្ចាស់ភាគហ៊ុនទាំងឡាយ ដើម្បីទទួលបាន ឬទិញភាគហ៊ុនរបស់អង្គភាពត្រឡប់មកវិញ

(គ) សាច់ប្រាក់បានមកពីការបោះលក់លិខិតបំណុល បំណុល លិខិតសញ្ញាប័ណ្ណ ប័ណ្ណបញ្ចាំ និងការសុំ ខ្ចីរយៈពេលខ្លី ឬវែងផ្សេងទៀត

(ឃ) ការសងបំណុលជាសាច់ប្រាក់ និង

(ង) ការទូទាត់សាច់ប្រាក់ដោយអ្នកជួលសម្រាប់កាត់បន្ថយបំណុល ដែលនៅជំពាក់ ដែលពាក់ព័ន្ធទៅនឹង ភតិសន្យាហិរញ្ញវត្ថុ ។

## ការរាយការណ៍លំហូរសាច់ប្រាក់បានមកពីសកម្មភាពប្រតិបត្តិការ

១៨ អង្គភាពមួយត្រូវធ្វើការរាយការណ៍លំហូរសាច់ប្រាក់ ដែលបានមកពីសកម្មភាពប្រតិបត្តិការ ដោយប្រើប្រាស់វិធីសាស្ត្រដូចខាងក្រោម÷

(ក) វិធីសាស្ត្រផ្ទាល់ ជាវិធីដែលលាតត្រដាងតាមលំដាប់ថ្នាក់សំខាន់ៗ នៃសាច់ប្រាក់ទទួល និងសាច់ប្រាក់ចំណាយសរុប ។

(ខ) វិធីសាស្ត្រប្រយោល ជាវិធីមួយដែលប្រាក់ចំណេញពិត ឬខាតពិត ត្រូវបានយកមកធ្វើនិយ័តភាព លើឥទ្ធិពលនៃប្រតិបត្តិការដែលមិនមានលក្ខណៈជាសាច់ប្រាក់ ការពន្យា ឬការបង្គរសាច់ប្រាក់បានទទួល ឬសាច់ប្រាក់ចំណាយ ដែលបានមកពីប្រតិបត្តិការអតីតកាល ឬអនាគត ព្រមទាំងធាតុទាំងឡាយរបស់ ចំណូល ឬចំណាយ ដែលពាក់ព័ន្ធជាមួយនឹង លំហូរសាច់ប្រាក់ពីការវិនិយោគ ឬហិរញ្ញប្បទាន ។

១៩ អង្គភាពត្រូវបានលើកទឹកចិត្ត ឱ្យរាយការណ៍លំហូរសាច់ប្រាក់បានមកពីសកម្មភាពប្រតិបត្តិការរបស់ខ្លួន ដោយប្រើវិធីសាស្ត្រផ្ទាល់។ វិធីសាស្ត្រផ្ទាល់ផ្តល់ព័ត៌មាន ដែលមានប្រយោជន៍ក្នុងការប៉ាន់ស្មានពី លំហូរសាច់ប្រាក់នាពេលអនាគត ហើយដែលព័ត៌មាននេះពុំអាចរកបានក្នុងវិធីសាស្ត្រ

ប្រយោល។ តាមវិធីសាស្ត្រផ្ទាល់ ព័ត៌មានស្តីពី លំដាប់ថ្នាក់សំខាន់ៗនៃសាច់ប្រាក់ទទួល និងសាច់ប្រាក់ចំណាយសរុបអាចទទួលបាន÷

(ក) ចេញពីកិច្ចបញ្ជីការគណនេយ្យរបស់អង្គភាព ឬ

(ខ) ដោយធ្វើនិយ័តភាពការលក់ ថ្លៃដើមលក់ (ចំណូលការប្រាក់ និងចំណូលប្រហាក់ប្រហែល និងចំណាយការប្រាក់ និងការចំណាយប្រហាក់ប្រហែល ចំពោះស្ថាប័នហិរញ្ញវត្ថុមួយ) ព្រមទាំងធាតុដទៃទៀតក្នុងរបាយការណ៍ប្រាក់ចំណេញសរុបពាក់ព័ន្ធនឹង:

(i) បម្រែបម្រួលនៃសន្និធិ និងគណនីអតិថិជន និងគណនីត្រូវសងនៃប្រតិបត្តិការក្នុងការិយបរិច្ឆេទ ។

(ii) ធាតុដែលមិនមានលក្ខណៈជាសាច់ប្រាក់ផ្សេងៗព្រមទាំង

(iii) ធាតុផ្សេងៗទៀតដែលធាតុនោះមានផលប៉ះពាល់ដល់លំហូរសាច់ប្រាក់នៃការវិនិយោគ ឬហិរញ្ញប្បទាន ។

២០ នៅក្រោមវិធីសាស្ត្រមិនផ្ទាល់លំហូរសាច់ប្រាក់សុទ្ធពី សកម្មភាពប្រតិបត្តិការត្រូវបានកំណត់ដោយធ្វើនិយ័តភាពប្រាក់ចំណេញ ឬខាត ចំពោះឥទ្ធិពលនៃ÷

(ក) បម្រែបម្រួលនៃសន្និធិ និងគណនីអតិថិជន និងគណនីត្រូវសងនៃប្រតិបត្តិការក្នុងកំឡុងគ្រានៃការិយបរិច្ឆេទ

(ខ) ធាតុមិនមែនសាច់ប្រាក់ ដូចជា រំលស់ សំវិធានធន ពន្ធពន្យាចំណេញ ឬខាតមិនទាន់សម្រេច នៃរូបិយប័ណ្ណ ប្រាក់ចំណេញមិនបែងចែកនៃក្រុមហ៊ុនញាតិសម្ព័ន្ធ និង

(គ) ធាតុផ្សេងៗទៀត ដែលធាតុនោះមានផលប៉ះពាល់ ដល់លំហូរសាច់ប្រាក់នៃការវិនិយោគ ឬហិរញ្ញប្បទាន ។

វិធីជំនួសមួយទៀតគឺ លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពប្រតិបត្តិការ អាចត្រូវបានបង្ហាញតាមវិធីសាស្ត្រមិនផ្ទាល់ ដោយបង្ហាញចំណូល ចំណាយដែលបានលាតត្រដាងក្នុង របាយការណ៍ប្រាក់ចំណេញសរុប និងបម្រែបម្រួលក្នុងការិយបរិច្ឆេទ នៃសន្និធិ និងគណនីអតិថិជន និងគណនីត្រូវសងនៃប្រតិបត្តិការ ។

## ការរាយការណ៍អំពីលំហូរសាច់ប្រាក់បានមកពីសកម្មភាពវិនិយោគ និងហិរញ្ញប្បទាន

២១ អង្គភាពមួយត្រូវរាយការណ៍តាមលំដាប់ថ្នាក់ចំបងៗនៃសាច់ប្រាក់ទទួលបាន និងសាច់ប្រាក់ចំណាយសរុប ដែលបានមកពីសកម្មភាពវិនិយោគ និងហិរញ្ញប្បទានឱ្យបានដាច់ដោយឡែកពីគ្នា លើកលែងតែលំហូរសាច់ប្រាក់ដែលបានពណ៌នាក្នុង កថាខណ្ឌ ២២ និង ២៤ ដែលត្រូវបានរាយការណ៍ផ្អែក លើមូលដ្ឋានពិត ។

## ការរាយការណ៍អំពីលំហូរសាច់ប្រាក់ផ្អែកតាមមូលដ្ឋានពិត

២២ លំហូរសាច់ប្រាក់ដែលកើតចេញពីសកម្មភាពប្រតិបត្តិការ វិនិយោគ និងហិរញ្ញប្បទាន អាចរាយការណ៍តាមមូលដ្ឋានពិតៈ

(ក) សាច់ប្រាក់ទទួលបាន និងសាច់ប្រាក់ចំណាយក្នុងនាមអតិថិជន នៅពេលដែលលំហូរសាច់ប្រាក់នោះឆ្លុះបញ្ចាំងពីសកម្មភាពរបស់អតិថិជន ជាជាងសកម្មភាពរបស់អង្គភាពឡើយ។

(ខ) សាច់ប្រាក់ទទួលបាន និងសាច់ប្រាកចំណាយចំពោះធាតុ ដែលអាចទទួលផលបានរហ័ស មានបរិមាណទឹកប្រាក់ធំ និងមានកាលកំណត់សងខ្លី ។

២៣ ឧទាហរណ៍នៃសាច់ប្រាក់ទទួលបាននិងសាច់ប្រាក់ចំណាយ ដែលបានចែង នៅក្នុងកថាខណ្ឌ ២២ ចំណុច (ក) មានដូចជា:

(ក) ការទទួល និងការទូទាត់សងវិញ នៃប្រាក់បញ្ញើរបស់ធនាគារ

(ខ) មូលនិធិដែលរក្សាទុកសម្រាប់អតិថិជន ដោយអង្គភាពវិនិយោគ ទុន មួយ

(គ) ថ្លៃជួល ដែលបានប្រមូលជំនួសម្ចាស់ទ្រព្យ និងត្រូវបង់ទៅឱ្យ ម្ចាស់ទ្រព្យ

២៣ក ឧទាហរណ៍ នៃសាច់ប្រាក់ទទួលបាន និងសាច់ប្រាក់ចំណាយ ដែលបាន ចែងនៅក្នុងកថាខណ្ឌ២២ ចំណុច (ខ) គឺជាការធ្វើបុរេប្រទាន និងការ ទូទាត់សងនូវ

(ក) ចំនួនប្រាក់ដើមដែលពាក់ព័ន្ធទៅនឹងប័ណ្ណឥណទានរបស់ អតិថិជន

(ខ) ការទិញ និងការលក់នៃការវិនិយោគ

(គ) កម្ចីរយៈពេលខ្លីផ្សេងៗឧទាហរណ៍ដូចជា កម្ចីទាំងឡាយណាដែល មានកាលកំណត់សងតិចជាង ឬស្មើ៣ខែ។

**២៤ ស្ថាប័នហិរញ្ញវត្ថុត្រូវរាយការណ៍តាមមូលដ្ឋានពិត នូវរាល់លំហូរសាច់ប្រាក់ ដែលបានមកពីសកម្មភាពដូចខាងក្រោម:**

**(ក) សាច់ប្រាក់ទទួលបាន និងសាច់ប្រាក់ចំណាយ សម្រាប់ការទទួល និងការទូរទាត់សងប្រាក់តម្កល់ក្នុងការិយបរិច្ឆេទកំណត់ថេរមួយ។**

**(ខ) ការដាក់ប្រាក់តម្កល់ និងការដកប្រាក់តម្កល់ចេញពីស្ថាប័នហិរញ្ញវត្ថុ ដទៃទៀត ។**

(គ) ប្រាក់បុរេប្រទាន និងកម្ចីផ្តល់ឱ្យអតិថិជន និងការទូទាត់សងប្រាក់បុរេប្រទាន និងប្រាក់កម្ចីទាំងនោះ ។

**លំហូរសាច់ប្រាក់នៃរូបិយប័ណ្ណបរទេស**

**២៥ លំហូរសាច់ប្រាក់ ដែលបានមកពីប្រតិបត្តិការជារូបិយប័ណ្ណបរទេស ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍របស់អង្គភាពជារូបិយប័ណ្ណក្នុងស្រុក ដោយប្រើប្រាស់អត្រាប្តូរប្រាក់រវាង រូបិយប័ណ្ណក្នុងស្រុក និងរូបិយប័ណ្ណបរទេស នៅកាលបរិច្ឆេទដែលមានលំហូរសាច់ប្រាក់ ។**

**២៦ លំហូរសាច់ប្រាក់របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធក្រៅប្រទេស ត្រូវប្តូរតាមអត្រាប្តូរប្រាក់រវាងរូបិយប័ណ្ណក្នុងស្រុក និងរូបិយប័ណ្ណបរទេស នៅកាលបរិច្ឆេទដែលមានលំហូរសាច់ប្រាក់ ។**

២៧ លំហូរសាច់ប្រាក់ជារូបិយប័ណ្ណបរទេស ត្រូវតែរាយការណ៍ឱ្យមានលក្ខណៈស្របទៅតាម ស.គ.អ ២១ *ផលប៉ះពាល់នៃការប្រែប្រួលអត្រាប្តូរប្រាក់បរទេស*។ ស្តង់ដានេះអនុញ្ញាត្តិឱ្យប្រើអត្រាប្តូរប្រាក់ប្រហាក់ប្រហែលនឹងអត្រាប្តូរប្រាក់ជាក់ស្តែង។ ជាឧទាហរណ៍ អត្រាប្តូរប្រាក់ជាមធ្យមសម្រាប់ការិយបរិច្ឆេទ អាចត្រូវបានប្រើប្រាស់សម្រាប់កត់ត្រាប្រតិបត្តិការជារូបិយ-ប័ណ្ណបរទេសឬ សម្រាប់ប្តូរលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធក្រៅប្រទេស។ ផ្ទុយទៅវិញ ស.គ.អ ២១ មិនអនុញ្ញាតឱ្យប្រើអត្រាប្តូរប្រាក់នៅចុងការិយបរិច្ឆេទនៃការធ្វើរបាយការណ៍ សម្រាប់ប្តូរលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធក្រៅប្រទេសទេ ។

២៨ ផលចំណេញ និងខាតមិនទាន់សម្រេច ដែលបណ្តាលមកពីបម្រែបម្រួលអត្រាប្តូរប្រាក់រូបិយប័ណ្ណបរទេស ពុំមែនជាលំហូរសាច់ប្រាក់ឡើយ។ ប៉ុន្តែផលប៉ះពាល់នៃបម្រែបម្រួលអត្រាប្តូរប្រាក់ចំពោះ សាច់ប្រាក់ និងសាច់

ប្រាក់ប្រហាក់ប្រហែលដែលមាន ឬដែលត្រូវដល់កំណត់សងជារូបិយប័ណ្ណបរទេស ត្រូវរាយការណ៍ក្នុងរបាយការណ៍លំហូរសាច់ប្រាក់ ដើម្បីផ្ទៀងផ្ទាត់ជាមួយនឹងសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែលនៅដើម និងចុងការិយ-បរិច្ឆេទ។ ចំនួននេះ គឺត្រូវបង្ហាញដាច់ដោយឡែកពីគ្នារវាង លំហូរសាច់ប្រាក់ដែលបានមកពី សកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគ និងសកម្មភាព ហិរញ្ញប្បទាន ព្រមទាំងត្រូវរួមបញ្ចូលនូវ ភាពខុសគ្នានៃលំហូរសាច់ប្រាក់ ដែលបានរាយការណ៍តាមអត្រាប្តូរប្រាក់នៅចុងការិយបរិច្ឆេទ ប្រសិនបើមាន។

**២៩** លុបចេញ

**៣០** លុបចេញ

## ការប្រាក់ និងភាគលាភ

**៣១ លំហូរសាច់ប្រាក់ដែលបានមកពីការទទួលបាន និងការបង់ការប្រាក់ និងភាគលាភ ត្រូវធ្វើការលាតត្រដាងដាច់ដោយឡែកពីគ្នា។ ធាតុនីមួយៗត្រូវតែចាត់ថ្នាក់ឱ្យមានលក្ខណៈស្របគ្នាដោយមិនប្រែប្រួលពីគ្រាមួយទៅគ្រាមួយទៀត ថាជាសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគ ឬសកម្មភាពហិរញ្ញប្បទាន ។**

៣២ ចំនួនការប្រាក់ដែលបានបង់សរុបនៅក្នុងគ្រាត្រូវតែលាតត្រដាងក្នុងរបាយ-ការណ៍លំហូរសាច់ប្រាក់ ថាតើវាត្រូវបានគេទទួលស្គាល់ថាជាចំណាយនៅក្នុងរបាយការណ៍លទ្ធផល ឬក៏ត្រូវបានធ្វើមូលធនកម្ម ស្របទៅតាម ស.គ.អ ២៣ *បន្ទុកលើប្រាក់កម្ចី*។

៣៣ ចំពោះស្ថាប័នហិរញ្ញវត្ថុមួយ ការប្រាក់ដែលបានបង់ ព្រមទាំងការប្រាក់ និងភាគលាភ ដែលត្រូវបានទទួល ជាធម្មតាត្រូវបានចាត់ថ្នាក់ជាលំហូរសាច់ប្រាក់ ដែលបានមកពីសកម្មភាពប្រតិបត្តិការ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពុំទាន់មានការព្រមព្រៀង លើការចាត់ថ្នាក់លំហូរសាច់ប្រាក់ទាំងនេះសម្រាប់ប្រភេទអង្គភាពដទៃទៀត។ ការប្រាក់ដែលបានបង់ ព្រមទាំងការប្រាក់ និងភាគលាភ ដែលត្រូវបានទទួលត្រូវចាត់ថ្នាក់ជាលំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពប្រតិបត្តិការ ពីព្រោះវាចូលរួមក្នុងការកំណត់ប្រាក់ចំណេញ ឬខាត ។ ជម្រើសមួយទៀត ការប្រាក់ដែលបានបង់ ព្រមទាំងការប្រាក់ និងភាគលាភដែលត្រូវបានទទួល ត្រូវបានចាត់ថ្នាក់ជាលំហូរសាច់ប្រាក់ហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់វិនិយោគរៀងៗគ្នាពីព្រោះវាទាំងនេះ គឺជាថ្លៃដើមនៃការទទួលបានធនធានហិរញ្ញវត្ថុ ឬផលទទួលបានលើការវិនិយោគ ។

៣៤ ភាគលាភដែលបានបង់ត្រូវចាត់ថ្នាក់ជាលំហូរសាច់ប្រាក់ហិរញ្ញវត្ថុ ពីព្រោះវាជាថ្លៃដើមនៃការទទួលបានធនធានហិរញ្ញវត្ថុ។ ជម្រើសមួយទៀតភាគលាភដែលបានបង់ អាចចាត់ថ្នាក់ជាចំណែកមួយនៃលំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ ដើម្បីជួយអ្នកប្រើប្រាស់វាយតម្លៃលទ្ធភាពរបស់អង្គ-ភាពក្នុងការបែងចែកភាគលាភចេញពីលំហូរសាច់ប្រាក់ប្រតិបត្តិការ ។

## ពន្ធលើប្រាក់ចំណេញ

**៣៥ លំហូរសាច់ប្រាក់ដែលបានមកពីពន្ធលើប្រាក់ចំណេញត្រូវបានបង្ហាញដាច់ដោយឡែកពីគ្នា និងត្រូវបានចាត់ថ្នាក់ជាលំហូរសាច់ប្រាក់ដែលបានមកពីសកម្មភាពប្រតិបត្តិការ លុះត្រាតែធាតុនោះ ត្រូវបានកំណត់ជាក់លាក់ទៅតាមសកម្មភាពហិរញ្ញប្បទាន និងសកម្មភាពវិនិយោគ ។**

៣៦ ពន្ធលើប្រាក់ចំណេញកើតមានលើប្រតិបត្តិការណាដែល នាំឱ្យលំហូរសាច់ប្រាក់កើតមាន ដោយចាត់ថ្នាក់ជាសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគឬសកម្មភាពហិរញ្ញប្បទាននៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់។ ខណៈដែលការចំណាយលើពន្ធ ត្រូវបានកំណត់ទៅតាម សកម្មភាពវិនិយោគ ឬសកម្មភាពហិរញ្ញប្បទាន លំហូរសាច់ប្រាក់ពាក់ព័ន្ធនឹង ពន្ធជារឿយៗមិនអាចធ្វើការកំណត់បានហើយអាចនឹងនាំឱ្យកើតឡើងក្នុងការិយបរិច្ឆេទខុសគ្នាពីប្រតិបត្តិការដើមនៃ លំហូរសាច់ប្រាក់ទៀតផង។ ដូច្នេះការបង់ពន្ធជាធម្មតាត្រូវបានចាត់ថ្នាក់ជា លំហូរសាច់ប្រាក់ ដែលបានមកពីសកម្មភាពប្រតិបត្តិការ ។ ប៉ុន្តែនៅពេលដែល គេអាចកំណត់លំហូរសាច់ប្រាក់ពន្ធបានទៅតាម ប្រតិបត្តិការនីមួយៗ ដែលធ្វើឱ្យលំហូរសាច់ប្រាក់កើនឡើង ដោយសារសកម្មភាពវិនិយោគ ឬសកម្មភាពហិរញ្ញប្បទាននោះ លំហូរសាច់ប្រាក់ពន្ធត្រូវចាត់ថ្នាក់ជា សកម្មភាពវិនិយោគ ឬសកម្មភាពហិរញ្ញប្បទានតាមភាពសមស្រប ។ នៅពេលដែលលំហូរសាច់ប្រាក់ពន្ធត្រូវបានបែងចែកចូលទៅក្នុង សកម្មភាពច្រើនជាងមួយត្រូវធ្វើការលាតត្រដាងចំនួនទឹកប្រាក់ដែលបានបង់ពន្ធសរុប ។

## ការវិនិយោគនៅក្នុងបុត្រសម្ព័ន្ធ និង សម្ព័ន្ធអាជីវកម្ម

៣៧ នៅពេលដែលធ្វើការកត់ត្រាគណនេយ្យចំពោះ ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ដោយប្រើប្រាស់វិធីសាស្រ្តមូល-និធិផ្ទាល់ឬវិធីសាស្រ្តថ្លៃដើមអ្នកវិនិយោគដាក់កម្រិតការរាយការណ៍របស់ខ្លួនក្នុងរបាយការណ៍លំហូរសាច់ប្រាក់នូវរាល់លំហូរសាច់ប្រាក់ រវាងវិនិយោគិនខ្លួនឯងនិងអ្នកទទួលបានការវិនិយោគពាក់ព័ន្ធនឹង ឧទាហរណ៍ដូចជា ភាគលាភនិងបុរេប្រទាន ។

៣៨ អង្គភាពដែលរាយការណ៍ពីអត្ថប្រយោជន៍របស់ខ្លួនក្នុង អង្គភាពអាជីវកម្មដែលមានការគ្រប់គ្រងរួមគ្នា (មើល ស.គ.អ ៣១ ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន) ដោយប្រើវិធីសាស្រ្តការរួមបញ្ចូលតាមសមាមាត្រ ត្រូវរួមបញ្ចូលក្នុងរបាយការណ៍លំហូរសាច់ប្រាក់រួមគ្នា នូវចំណែកសមាមាត្រនៃលំហូរសាច់ប្រាក់ដែលមាននៅក្នុងអង្គភាពអាជីវកម្ម ដែលមានការគ្រប់គ្រងរួមគ្នា។ អង្គភាព ដែលរាយកាណ៍ពីអត្ថប្រយោជន៍តាមវិធីសាស្រ្តមូលនិធិផ្ទាល់ត្រូវបញ្ចូលទៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់របស់ខ្លួន នូវលំហូរសាច់ប្រាក់ពាក់ព័ន្ធនឹងការវិនិយោគក្នុងអង្គភាពអាជីវកម្មដែលមានការគ្រប់គ្រងរួមគ្នា និងការបែងចែក និងការទទួល ឬការបង់ប្រាក់ រវាងអង្គភាពខ្លួនឯង និងអង្គភាពអាជីវកម្មដែលមានការគ្រប់គ្រងរួមគ្នា ។

## ការប្រែប្រួលភាគកម្មកម្មសិទ្ធិ ក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ និងអាជីវកម្មផ្សេងៗ

៣៩ **លំហូរសាច់ប្រាក់សរុបដែលកើតឡើងពីការទទួលបានឬការបាត់បង់ការគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬអាជីកម្មផ្សេងៗ ត្រូវបង្ហាញដោយឡែកនិងចាត់ថ្នាក់ជាសកម្មភាពវិនិយោគ ។**

៤០ អង្គភាពត្រូវលាតត្រដាងជារួម ពាក់ព័ន្ធនឹងការទទួលបាន ឬការបាត់បង់ការគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬអាជីកម្មផ្សេងៗ នៅក្នុងការិយបរិច្ឆេទនីមួយៗដូចខាងក្រោម÷

(ក) តម្លៃតបស្នងសរុបដែលបានបង់ និងទទួល

(ខ) ភាគខ្លះនៃតម្លៃតបស្នងរួមមានសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល

(គ) ចំនួនសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែលនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬអាជីកម្មផ្សេងៗ ដែលការគ្រប់គ្រងដែលត្រូវបានទទួល ឬបាត់បង់ និង

(ឃ) ចំនួនទ្រព្យសកម្ម និងបំណុល មិនមែនជាសាច់ប្រាក់ ឬសាច់ប្រាក់ប្រហាក់ប្រហែលក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬអាជីកម្មផ្សេងៗ ដែលការគ្រប់គ្រងដែលត្រូវបានទទួល ឬបាត់បង់ដោយសង្ខេបតាមយថាប្រភេទសំខាន់ៗ ។

៤១ ការបង្ហាញដាច់ដោយឡែក ជាធាតុតែមួយអំពីផលប៉ះពាល់នៃលំហូរសាច់ប្រាក់ដល់ការទទួលបាន ឬការបាត់បង់ការគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬអាជីកម្មផ្សេងៗ រួមជាមួយនឹង ការលាតត្រដាងដោយឡែក នូវចំនួនបំណុល និងទ្រព្យសកម្មដែលបានទិញ ឬលក់ចេញ ជួយឱ្យដឹងពីភាពខុសគ្នារវាងលំហូរសាច់ប្រាក់ បានមកពីសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគ សកម្មភាពហិរញ្ញប្បទានផ្សេងៗ។ ផលប៉ះពាល់នៃលំហូរសាច់ប្រាក់ដល់ការបាត់បង់ការគ្រប់គ្រង មិនត្រូវដកចេញពីផលប៉ះពាល់ដែលនាំឱ្យទទួលបានការគ្រប់គ្រងឡើយ ។

៤២ ចំនួនទឹកប្រាក់សរុបដែលបានបង់និងបានទទួល ដូចជាតម្លៃតបស្នងសំរាប់ទទួលបានឬការបាត់បង់ ការគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬអាជីកម្មផ្សេងៗ ត្រូវបានរាយការណ៍ ក្នុងរបាយការណ៍លំហូរសាច់ប្រាក់ ដោយដកចេញនូវសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល ដែលបានទិញ ឬលក់ចេញ ដែលជាចំណែកមួយនៃប្រតិបត្តិការ ព្រឹត្តិការណ៍ ឬបម្រែបម្រួលលក្ខខណ្ឌ។

៤២ក លំហូរសាច់ប្រាក់ដែលបានមកពីបម្រែបម្រួលភាគកម្មជាកម្មសិទ្ធក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលមិនឈានទៅដល់ការបាត់បង់ការគ្រប់គ្រងត្រូវចាត់ថ្នាក់ជាលំហូរសាច់ប្រាក់បានមកពីសកម្មភាពហិរញ្ញប្បទាន ។

៤២ខ បម្រែបម្រួលភាគកម្ម ជាកម្មសិទ្ធក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលមិនឈានដល់ការបង់ការគ្រប់គ្រង ដូចជាការទិញ ឬលក់ដោយព្រឹត្តិការណ៍ ដែលកើតឡើងពីមុនរបស់ក្រុមហ៊ុនមេចំពោះឧបករណ៍មូលនិធិផ្ទាល់របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវកត់ត្រាជា ប្រតិបត្តិការមូលធនកម្ម (មើល ស.គ.អ ២៧ *របាយការណ៍ហិរញ្ញវត្ថុរួមគ្នា និងដាច់ដោយឡែក* (ត្រូវបានកែប្រែក្នុងឆ្នាំ២០០៨) ។ អាស្រ័យហេតុនេះ លទ្ធផលលំហូរសាច់ប្រាក់ត្រូវបានចាត់ថ្នាក់តាមមធ្យោបាយដូចគ្នាទៅនឹងប្រតិបត្តិការជាមួយនឹងម្ចាស់ ដូចដែលបានពិពណ៌នាក្នុងកថាខណ្ឌ១៧ ។

## ប្រតិបត្តិការមិនមែនសាច់ប្រាក់

**៤៣ ប្រតិបត្តិការវិនិយោគនិងហិរញ្ញប្បទានដែលមិនត្រូវការប្រើប្រាស់សាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែលត្រូវដកចេញពីរបាយការណ៍លំហូរសាច់ប្រាក់។ ប្រតិបត្តិការទាំងនេះ ត្រូវលាតត្រដាងនៅក្នុងកន្លែង**

**ណាមួយផ្សេងទៀតនៃរបាយការណ៍ហិរញ្ញវត្ថុ ធ្វើយ៉ាងណាផ្តល់នូវព័ត៌មានទាំងអស់អំពីសកម្មភាពវិនិយោគ និងសកម្មភាពហិរញ្ញប្បទាននានា ។**

៤៤ សកម្មភាពហិរញ្ញប្បទាន និងវិនិយោគជាច្រើនពុំមានឥទ្ធិពលផ្ទាល់លើលំហូរសាច់ប្រាក់ពេលបច្ចុប្បន្នទេ ទោះបីជាសកម្មភាពទាំងនោះជះឥទ្ធិពលដល់រចនាសម្ព័ន្ធទ្រព្យសកម្ម និងមូលធនរបស់អង្គភាពក្តី។ ការមិនរាប់បញ្ចូលប្រតិបត្តិការមិនមែនសាច់ប្រាក់ ទៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់គឺសមស្រប ជាមួយគោលបំណងនៃរបាយការណ៍លំហូរសាច់ប្រាក់ ពីព្រោះធាតុទាំងនេះ មិនមែនពាក់ព័ន្ធនឹង លំហូរសាច់ប្រាក់ នៅការិយបរិច្ឆេទបច្ចុប្បន្ន។ ឧទាហរណ៍នៃប្រតិបត្តិការមិនមែនសាច់ប្រាក់មានៈ

(ក) ការទិញទ្រព្យសកម្មតាមវិធីទទួលយកបំណុលផ្ទាល់ ឬតាមវិធីនៃភតិសន្យាហិរញ្ញប្បទាន។

(ខ) ការទិញអង្គភាពមួយតាម មធ្យោបាយនៃការបោះផ្សាយមូលធនផ្ទាល់ និង

(គ) ការបំឡែងបំណុលទៅជាមូលធនផ្ទាល់

## សមាសធាតុនៃសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល

៤៥ **អង្គភាពមួយត្រូវលាតត្រដាងសមាសភាគនៃសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល និងត្រូវបង្ហាញនូវការផ្ទៀងផ្ទាត់នៃចំនួននៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ ជាមួយនឹងធាតុសមមូលដែលបានរាយការណ៍ នៅក្នុងរបាយការណ៍ស្ថានភាព ។**

៤៦ ដោយពិចារណាទៅលើការអនុវត្តន៍ការគ្រប់គ្រងសាច់ប្រាក់ និងការរៀបចំរបស់ធនាគារ នៅជុំវិញពិភពលោក និងដើម្បីអនុលោមតាម ស.គ.អ ១

*ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ* អង្គភាពមួយត្រូវលាតត្រដាងពីគោល-នយោបាយដែលគេយកមកប្រើប្រាស់ដើម្បីកំណត់សមាសភាគសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល ។

៤៧ ផលប៉ះពាល់នៃ បម្រែបម្រួលមួយចំនួន ក្នុងគោលនយោបាយសម្រាប់កំណត់សមាសភាគសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល (ឧទាហរណ៍ដូចជាបម្រែបម្រួលនៅក្នុងចំណាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុដែលពីមុនគេគិតថាជាផ្នែកមួយនៃ ចង្កោមវិនិយោគរបស់អង្គភាព) ត្រូវរាយការណ៍ដោយយោងតាម ស.គ.អ ៨ *គោលនយោបាយគណនេយ្យ បម្រែបម្រួលនៃការប៉ាន់ស្មាន និងកំហុសឆ្គងគណនេយ្យ*។

## ការលាតត្រដាងពីព័ត៌មានផ្សេងៗ

**៤៨ អង្គភាពមួយត្រូវលាតត្រដាង ដោយភ្ជាប់ជាមួយនូវការអត្ថាធិប្បាយរបស់ថ្នាក់គ្រប់គ្រង អំពីចំនួនសមតុល្យសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល ដែលរក្សាទុកដោយអង្គភាពហើយ ដែលមិនមែន សម្រាប់ការប្រើប្រាស់ ក្នុងក្រុមឡើយ ។**

៤៩ មានករណីផ្សេងៗ ដែលសមតុល្យសាច់ប្រាក់ ឬ សាច់ប្រាក់ប្រហាក់ប្រហែល រក្សាទុកដោយអង្គភាព ហើយមិនមែនសម្រាប់ប្រើប្រាស់ក្នុងក្រុមឡើយ។ ឧទាហរណ៍ដូចជា សមតុល្យសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល មាននៅក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលដំណើរការក្នុងប្រទេសមួយដែលត្រួតពិនិត្យលើការដោះដូរ ឬការដាក់កំរិតតាមច្បាប់ផ្សេងៗ ដែលនៅពេលនោះសមតុល្យសាច់ប្រាក់មិនអាចប្រើប្រាស់ជាទូទៅដោយក្រុមហ៊ុនមេ ឬក្រុមហ៊ុនបុត្រសម្ព័ន្ធផ្សេងទៀតឡើយ។

៥០ ព័ត៌មានបន្ថែមអាចមានប្រយោជន៍ចំពោះអ្នកប្រើប្រាស់ ក្នុងការយល់ដឹង អំពីស្ថានភាពហិរញ្ញវត្ថុ និងសន្ទនីយភាពរបស់អង្គភាពមួយ។ ការបង្ហាញ ព័ត៌មាននេះ រួមជាមួយនឹងសេចក្តីអធិប្បាយរបស់គណៈគ្រប់គ្រង ត្រូវបាន លើកទឹកចិត្ត ហើយអាចរួមមានៈ

(ក) បរិមាណនៃឧបករណ៍ឥណទានមិនទាន់ប្រើប្រាស់ ដែលអាចដក យកមកប្រើប្រាស់ សម្រាប់ប្រតិបត្តិការនាពេលអនាគត និងដើម្បី ទូទាត់ការសន្យាមូលធន ដែលចង្អុលបង្ហាញនូវកំហិតណាមួយ លើការប្រើប្រាស់ឧបករណ៍ទាំងនេះ ។

(ខ) បរិមាណសរុបនៃ លំហូរសាច់ប្រាក់ ដែលបានមកពី សកម្មភាព នីមួយៗ នៃសកម្មភាពប្រតិបត្តិការ វិនិយោគ និងហិរញ្ញវត្ថុ ដែល ពាក់ព័ន្ធទៅនឹងភាគកម្មនៃក្រុមហ៊ុនដាក់រួមគ្នា ដែលបានរាយការណ៍ ដោយប្រើវិធីសាស្ត្ររួមគ្នាតាមវិធីសមាមត្រ ។

(គ) បរិមាណសរុបនៃ លំហូរសាច់ប្រាក់ ដែលតំណាងឱ្យ កំណើន សមត្ថភាពប្រតិបត្តិការ ដាច់ដោយឡែកពីលំហូរសាច់ប្រាក់ទាំង ឡាយដែលត្រូវការ ដើម្បីរក្សាសមត្ថភាពប្រតិបត្តិការ និង

(ឃ) ទឹកប្រាក់នៃលំហូរសាច់ប្រាក់ដែលកើតចេញពី សកម្មភាពប្រតិ- បត្តិការវិនិយោគ និងហិរញ្ញប្បទានរបស់ចំណែកអាជីវកម្មនីមួយៗ ដែលអាចរាយការណ៍បាន (មើល ស.រ.ហ.អ ៨ *ចំណែកនៃ ប្រតិបត្តិការ* ) ។

៥១ ការលាតត្រដាងដាច់ដោយឡែកពីលំហូរសាច់ប្រាក់ ដែលតំណាងឱ្យ កំណើនសមត្ថភាពប្រតិបត្តិការ និងលំហូរសាច់ប្រាក់ទាំងឡាយ ដែល ត្រូវការដើម្បីរក្សាសមត្ថភាពប្រតិបត្តិការ មានសារៈប្រយោជន៍ ជួយអ្នក

ប្រើប្រាស់ ដើម្បីកំណត់ថា តើអង្គភាពកំពុងវិនិយោគគ្រប់គ្រាន់ក្នុងការរក្សាសមត្ថភាពប្រតិបត្តិការរបស់ខ្លួនឬទេ ។ អង្គភាពមួយដែលមិនវិនិយោគឱ្យបានគ្រប់ គ្រាន់ក្នុងការរក្សាសមត្ថភាពប្រតិបត្តិការ របស់ខ្លួនអាចនឹងធ្វើឱ្យមានការ វិនិច្ឆ័យខុសអំពីចំណេញភាពពេលអនាគត ដើម្បីតែសន្ទនីយភាពនាពេលបច្ចុប្បន្ន និងការបែងចែកទៅឱ្យម្ចាស់ ។

៥២ ការបង្ហាញលំហូរសាច់ប្រាក់តាមផ្នែកអាជីវកម្ម អាចអនុញ្ញាតឱ្យ អ្នកប្រើប្រាស់ទទួលបានការយល់ដឹងបន្ថែមពី ទំនាក់ទំនងរវាងលំហូរសាច់ប្រាក់របស់អាជីវកម្មទាំងមូលនិងលំហូរសាច់ប្រាក់តាមផ្នែកនីមួយៗ ព្រមទាំងភាពអាចរកបាន និងភាពប្រែប្រួលនៃលំហូរសាច់ប្រាក់តាមផ្នែក ។

## ថ្ងៃចូលជាធរមាន

៥៣ ស្តង់ដានេះអាចអនុវត្តបានសម្រាប់របាយការណ៍ហិរញ្ញវត្ថុ ដែលការិយ-បរិច្ឆេទចាប់ផ្តើម ឬក្រោយ ថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៤ ។

៥៤ ស.គ.អ ២៧ ( បានកែប្រែក្នុងឆ្នាំ២០០៨) បានកែប្រែកថាខណ្ឌ ៣៩-៤២ ហើយបានបន្ថែម កថាខណ្ឌ ៤២ក និង៤២ខ ។ អង្គភាពត្រូវប្រើប្រាស់ការកែប្រែទាំងនោះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើម ឬក្រោយពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ។ ប្រសិនបើអង្គភាពមួយអនុវត្តន៍ ស.គ.អ ២៧ (បានកែប្រែនៅឆ្នាំ២០០៨ ) សម្រាប់ការិយបរិច្ឆេទពីមុន ការកែប្រែត្រូវបានអនុវត្តន៍សម្រាប់ការិយបរិច្ឆេទពីមុន។ ការកែប្រែត្រូវបានអនុវត្តន៍ឆ្លុះបញ្ចាំងពីអតីតកាល ។

៥៥ កថាខណ្ឌ ១៤ ត្រូវបានកែប្រែដោយការធ្វើឱ្យ *ប្រសើរឡើង ចំពោះ ស.រ.ហ.អ* បានចេញផ្សាយក្នុង ខែឧសភា ឆ្នាំ២០០៨ ។ អង្គភាពមួយត្រូវ

អនុវត្តន៍ការកែប្រែសម្រាប់ការិយបរិច្ឆេប្រចាំឆ្នាំ ដែលចាប់ផ្តើម ឬក្រោយ ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩។ ការអនុវត្តន៍ពីមុនត្រូវបានអនុញ្ញាត្ត។ ប្រសិនបើ អង្គភាពមួយអនុវត្តការកែប្រែសម្រាប់ការិយបរិច្ឆេទពីមុនវាត្រូវ លាតត្រដាងការពិតនេះ ហើយអនុវត្តកថាខណ្ឌ៦៨ក របស់ស.គ.អ ១៦។

៥៦ កថាខណ្ឌ ១៦ ត្រូវបានកែប្រែ ដោយការធ្វើឱ្យ *ប្រសើរឡើង ចំពោះ ស.រ.ហ.អ* បានចេញផ្សាយក្នុងខែ មេសា ឆ្នាំ២០០៩ អង្គភាពមួយ ត្រូវអនុវត្តការកែប្រែសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើមឬក្រោយ ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០។ ការអនុវត្តន៍ពីមុនត្រូវបានអនុញ្ញាត។ ប្រសិនបើ អង្គភាពមួយអនុវត្តការកែប្រែសម្រាប់ការិយបរិច្ឆេទពីមុនវាត្រូវ លាតត្រដាងការពិតនេះ ។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាសយដ្ឋាន៖ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែល៖ info@naccambodia.gov.kh | គេហទំព័រ៖ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ